# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណីលេខ៖៣៦១
ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២
សាលក្រមលេខ ០១២ /២២"ធ"
ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

**បានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**
**នៅថ្ងៃទី២២ ខែសីហា ២០២២ និងប្រកាសសាលក្រមដោយមិនឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់**
**នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៣៦១ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២**

**ដោយមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**រវាងដើមចោទ ៖**

ឈ្មោះ [redacted] **យ៉ាំ** ភេទប្រុស អាយុ ៦៧ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted]។

**និងសហចុងចម្លើយ ៖**

ឈ្មោះ [redacted] **គឹមសាន** ភេទប្រុស កើតថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៦ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] ធរី កើតថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៦២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋាននៅ [redacted]

ដែលមានលោក [redacted] លោក [redacted], លោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអណត្តិឱ្យឈ្មោះ [redacted] គឹមសាន ដែលមានការិយាល័យមេធាវី [redacted] មានអាសយដ្ឋានអាគារលេខ [redacted]។

## អង្គហេតុ និងការអះអាងរបស់ភាគី

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖**

១.សុំរំលាយកិច្ចសន្យាលក់-ទិញ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ២៣៦មព ចុះនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលចុះហត្ថលេខាដោយលោក [redacted] ជាអភិបាលនៃគណៈអភិបាលស្រុកមុខកំពូល។

២.សុំទទួលស្គាល់ឈ្មោះ [redacted] យ៉ាំ ភេទប្រុស អាយុ៦៦ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០២០៣៣១៣៦១ មានទីលំនៅ [redacted] ជាម្ចាស់កម្មសិទ្ធិលើដីដែលមានទំហំ៣៥០៨៥៧ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅចំណុចមាត់គោកអូររាំងទោងមានព្រំប្រទល់៖



Scanned with CamScanner

-ខាងជើងទល់នឹងព្រែក -ខាងត្បូងទល់នឹងដីឈ្មោះ [redacted] គីមឡេង និងដី [redacted] ឡេវ

-ខាងកើតទល់នឹងដី [redacted] វ៉េត -ខាងលិចទល់នឹងដី [redacted] គីមសាន

**ខ. អង្គហេតុ និងចំណុចវិវាទ**

**ខ.១.** រឿងក្តីនេះដើមចោទឈ្មោះ [redacted] **យ៉ាំ** បានធ្វើសេចក្តីថ្លែងការណ៍ក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖ ខ្លួនសូមរក្សាការទាមទារដូចដែលមានក្នុងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ ទុកជាបានការដដែល។ សូមបញ្ជាក់ជូនតុលាការផងដែរថា ការដែលខ្លួនសុំទទួលស្គាល់ជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ពីព្រោះការទិញលក់នូវដីមួយកន្លែងដែលមានទំហំ ៣៥០៨៥៧ ម៉ែត្រការ៉េ ក្នុងតម្លៃ USD ៣.០០០ក្នុងមួយហិចតា ជាមួយឈ្មោះ [redacted] គីមសាន និងឈ្មោះ [redacted] ធរី មិនបានប្រគល់ប្រាក់មកឱ្យខ្លួនទេ។

**ខ.២.(លោក [redacted], លោក [redacted] អវត្តមាន) លោក [redacted] និងលោក [redacted]** ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] **គីមសាន** បានធ្វើសេចក្តីថ្លែងការណ៍ក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា៖ សូមប្រានចោលនូវពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ និងពាក្យសុំកែតម្រូវពាក្យបណ្តឹងចុះនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] យ៉ាំ ទាំងស្រុងដោយមូលហេតុ ដើមបណ្តឹងបានថ្លោះសិទ្ធិក្នុងការប្តឹងសុំរំលាយកិច្ចសន្យាវាងកូនក្តីខ្ញុំ និងឈ្មោះ [redacted] យ៉ាំ ពីព្រោះការប្តឹងរបស់ដើមចោទបានផុតអាជ្ញាយុលកាលនៃការរលត់សិទ្ធិ រំលាយកិច្ចសន្យាដោយយោងតាមបញ្ញត្តិមាត្រា៤១៣នៃក្រមរដ្ឋប្បវេណី។ ម្យ៉ាងទៀតការទិញលក់ កូនក្តីរបស់ខ្ញុំបានបំពេញកាតព្វកិច្ចចប់សព្វគ្រប់រួចហើយ ទើបដើមចោទដើមចោទធ្វើការផ្ទេរសិទ្ធិដីកាន់កាប់ដីនេះ មកឱ្យកូនក្តីរបស់ខ្លួន ក៏បានលក់បន្តទៅឱ្យតតិយជនផ្សេងទៀតរួចហើយដែរ។

**គ. ភារពិនិត្យភស្តុតាង**

-ពាក្យបណ្តឹងចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] យ៉ាំ។

-ពាក្យសុំកែតម្រូវពាក្យបណ្តឹងលេខ ៨០២ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] យ៉ាំ។

-កំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០២២។

-កំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២២។

-ឯកសារផ្សេងៗទៀតដែលមានភ្ជាប់ក្នុងសំណុំរឿង។

## សំអាងហេតុ

យោងតាមលទ្ធផលនៃការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងសំណុំរឿងនេះរួចមកតុលាការ៖

**១.យល់ឃើញថា** ដើមចោទបានដាក់ពាក្យបណ្តឹង ចុះនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ ដោយពុំមានសរសេរអំពីចំណុចភាគីចុងចម្លើយ ហើយតុលាការបានបង្គាប់ឱ្យដើមចោទកែតម្រូវពាក្យបណ្តឹងតាមរយៈដីកាសម្រេចបង្គាប់ឱ្យកែតម្រូវពាក្យបណ្តឹងចុះនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ហើយដើមចោទបានដាក់ពាក្យសុំកែតម្រូវពាក្យបណ្តឹងចុះនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ មកតុលាការដោយបានយកឈ្មោះ [redacted] គីមសាន ភេទប្រុស អាយុ៦៦ឆ្នាំ និងឈ្មោះ [redacted] ធរី ភេទស្រី មានទីលំនៅបច្ចុប្បន្ន [redacted]

[redacted] ជាសហចុងចម្លើយ និងសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារៈ១.សុំរំលាយកិច្ចសន្យាលក់-ទិញ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ២៣៦មព ចុះនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលចុះហត្ថលេខាដោយលោក [redacted] សំ ជាអភិបាលនៃគណៈអភិបាលស្រុកមុខកំពូល និង២.សុំទទួលស្គាល់ឈ្មោះ [redacted] យ៉ាំ ភេទប្រុស អាយុ៦៦ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ០២០៣៣១៣៦១ មានទីលំនៅ[redacted] ជាម្ចាស់កម្មសិទ្ធិលើដីដែលមានទំហំ ៣៥០៨៥៧ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅចំណុចមាត់គោកអូររាំងទោងមានព្រំប្រទល់ៈ

**-ខាងជើងទល់នឹងព្រែក** **-ខាងត្បូងទល់នឹងដីឈ្មោះ [redacted]គីមឡេង និងដី [redacted] ឡេវ**

**-ខាងកើតទល់នឹងដី [redacted] រ៉េត** **-ខាងលិចទល់នឹងដី [redacted] គីមសាន**

នៅភូមិអន្លង់ស្លែង ឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល។

**២.យល់ឃើញថា** តាមរយៈដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទាំង២លើក ចុះនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២២ និងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ដើមចោទនៅតែរក្សាការទាមទារដូចមានក្នុងពាក្យសុំកែតម្រូវពាក្យបណ្តឹងចុះនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២ ទុកជាបានការដដែល។

៣.តុលាការពិនិត្យឃើញថាការទាមទារចម្បងក្នុងចំណុចទី១ របស់ដើមចោទដែលសុំរំលាយកិច្ចសន្យាលក់ទិញ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ២៣៦មព ចុះនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១២ គឺជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ក្នុងការទាមទារ ហើយដែលសិទ្ធរំលាយកិច្ចសន្យា មិនមែនជាអ្វីដែលត្រូវទាមទារតាមផ្លូវបណ្តឹងដើម្បីឱ្យតុលាការសម្រេចឡើយ ហេតុនេះតុលាការយល់ឃើញថាការទាមទារនេះមិនមានផលប្រយោជន៍នៃបណ្តឹងតាមបញ្ញត្តិ មាត្រា៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ។ ដោយឡែកការទាមទារក្នុងចំណុចទី២ ឃើញថាបណ្តឹងទាមទារឱ្យទទួលស្គាល់ជាកម្មសិទ្ធិករនេះ តុលាការយល់ឃើញថាការទាមទារនេះមិនអាចកំណត់បានថាជាការទាមទារក្នុងបណ្តឹងប្រភេទណាមួយឱ្យបានច្បាស់លាស់ក្នុងចំណោមបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក បណ្តឹងទាមទារឱ្យបញ្ជាក់ និងបណ្តឹងទាមទារឲ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត ហើយឃើញថា ការទាមទារចំណុចទី២នេះ ធ្វើឡើងដោយផ្អែកលើការទាមទារក្នុងចំណុចទី១ខាងលើ ដែលត្រូវបានតុលាការវាយតម្លៃថា មិនមានផលប្រយោជន៍ក្នុងការធ្វើបណ្តឹងតាមមាត្រា៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤.ផ្អែកតាមអង្គហេតុខាងលើ ឃើញថាបណ្តឹងដែលដើមចោទបានដាក់មកនេះ ជាបណ្តឹងដែលមានលក្ខណៈផ្ទុយច្បាប់ ដោយសារតែគ្មានផលប្រយោជន៍ក្នុងការធ្វើបណ្តឹង ហើយដោយផ្អែកតាមមាត្រា៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការអាចលើកបណ្តឹងដែលមានលក្ខណៈផ្ទុយច្បាប់ ហើយមិនអាចកែតម្រូវបានដោយសាលក្រមដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន។

៥. ផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## សេចក្តីសម្រេចបញ្ចប់

១. លើកចោលពាក្យបណ្តឹងចុះនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ និងពាក្យសុំកែតម្រូវពាក្យបណ្តឹងចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២ របស់ដើមចោទឈ្មោះ [redacted] យ៉ាំ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

ក្រឡាបញ្ជីលោក **ស្រ៊ាវ វ៉ាវុធ** (វ.ស)

Scanned with CamScanner

សាលក្រមនេះ ប្រកាសជាសាធារណៈនៅ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ចំពោះមុខដើមចោទ និងចុងចម្លើយឈ្មោះ [redacted] គឹមសាន និងកំបាំងមុខចុងចម្លើយឈ្មោះ [redacted] ធរី ។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះតាមការកំណត់របស់ច្បាប់ ។

ថ្ងៃ ចន្ទ ១០ រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

កណ្តាល,ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២

**ចៅក្រម**

ហត្ថលេខា និង ត្រា [redacted]

---

"បានថតចម្លងសាលក្រមលេខ ០១២/២២ "ធ" ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២២ត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ ចន្ទ ១០ រោច ខែស្រាពណ៍ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

កណ្តាល,ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ និងឯកភាព

**ចៅក្រមជំនុំជម្រះ**

[redacted]

ក្រឡាបញ្ជីលោក **ស្រាវ វ៉ាវុធ** (វ.ស)

Scanned with CamScanner